ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

០៧ ឧសភា ១១

សូមគោរពជូន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**តាមរយៈ ÷ ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**កម្មវត្ថុ** ÷ របាយការណ៍បញ្ចប់ការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប និងលទ្ធផលសំខាន់ៗរបស់គម្រោង។

គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប (TSSLP) គឺជាគម្រោងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានថវិកាសរុបចំនួន ២០.៣លានដុល្លារអាមេរិក បានមកពីការគាំទ្រមូលនិធិពីបីប្រភព គឺធនាគារអភិវឌ្ឍន៍អាស៊ី (១៥ លានដុល្លារ) រដ្ឋាភិបាលប្រទេសហ្វាំងឡង់ (៤.៧៤ លានដុល្លារ) និងរាជរដ្ឋាភិបាលកម្ពុជា (0.៦ លានដុល្លារ)។ គម្រោងនេះ មានគោលបំណងសំខាន់គឺដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ដោយបង្កើនលទ្ធភាពទទួលបាននូវផលប្រយោជន៍ពីកិច្ចអភិវឌ្ឍមូលដ្ឋាន និងលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅក្នុងខេត្តចំនួន៥ ជុំវិញបឹងទន្លេសាប គឺខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ។ តំបន់គោលដៅរបស់គម្រោងនេះ គឺស្ថិតនៅក្នុងតំបន់ទ្រនាប់ និងតំបន់ស្នូលនៃបឹងទន្លេសាបដែលមានឃុំគោលដៅចំនួន៣៧ ភូមិសរុបចំនួន៣១៦។ គោលការណ៍សំខាន់របស់គម្រោងនេះ គឺការអនុវត្តតាមគោលនយោបាយវិមជ្ឈការ ផ្តោតទៅលើប្រព័ន្ធកិច្ចដំណើរការ និងនីតិវិធីសម្រាប់កិច្ចអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ ក្រោមក្របខ័ណ្ឌនៃការផ្តួចផ្តើមរបស់សហគមន៍មូលដ្ឋាន។

ក្រសួងមហាផ្ទៃគឺជាស្ថាប័នប្រតិបត្តិគម្រោង ដោយសហការជាមួយស្ថាប័នអនុវត្តពាក់ព័ន្ធផ្សេងទៀតរួមមាន ក្រសួងបរិស្ថាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (CARD) ។ ការអនុវត្តគម្រោងនេះត្រូវបានចាប់ផ្តើមនៅឆ្នាំ២០០៦ និងបានបញ្ចប់ជាស្ថាពរនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ដោយសម្រេចបានលទ្ធផលតាមគោលបំណងដែលបានរំពឹងទុករបស់គម្រោង។

## ១-លទ្ធផលសម្រេចបាន

<u>ការរៀបចំបង្កើត និងអនុវត្តមូលនិធិទ្រទ្រង់ជីវភាពសហគមន៍</u> ៖ លក្ខណៈសំខាន់នៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនេះ គឺការបង្កើតមូលនិធិទ្រទ្រង់ជីវភាពសហគមន៍ ដើម្បីវិភាជន៍ និងផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅក្នុងលក្ខណៈជាកញ្ចប់ថវិកា។ ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅត្រូវបានផ្តល់សិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់មូលនិធិនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ និងសហគមន៍ ដែលបានកំណត់នៅក្នុងផែនការ

អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន ផ្អែកតាមប្រព័ន្ធរៀបចំផែនការ និងប្រព័ន្ធអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលមានជាធរមាន។

ថវិការបស់គម្រោងចំនួន ១២.៣លានដុល្លារ ត្រូវបានរៀបចំបង្កើតជាមូលនិធិទ្រទ្រង់ជីវភាពសហគមន៍ និងបាន ធ្វើការវិភាជន៍ឱ្យទៅឃុំ សង្កាត់គោលដៅនីមួយៗ តាមរូបមន្តដែលបានប្រើប្រាស់សម្រាប់វិភាជន៍មូលនិធិឃុំ សង្កាត់។ ឃុំគោលដៅនីមួយៗទទួលបានការវិភាជន៍មូលនិធិទ្រទ្រង់ជីវភាពសហគមន៍នេះជាមធ្យមប្រមាណ ៣០ម៉ឺនដុល្លារ។ ក្នុង រយៈពេលនៃអនុវត្តគម្រោង មូលនិធិទ្រទ្រង់ជីភាពសហគមន៍ទាំង ១២.៣លានដុល្លារនេះ ត្រូវបានផ្ទេរទាំងស្រុងឱ្យ ទៅឃុំ សង្កាត់គោលដៅ ហើយឃុំ សង្កាត់គោលដៅនីមួយៗបានប្រើប្រាស់មូលនិធិដែលខ្លួនទទួលបានអស់១០០%។

ក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រើប្រាស់មូលនិធិទ្រទ្រង់ជីវភាព សហគមន៍នេះ មានគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូច គម្រោងបង្កើតប្រាក់ចំណូល និងគម្រោងគាំទ្រសហគមន៍ នេសាទ សរុបប្រមាណជាង ១.៤០០គម្រោង ត្រូវបានរៀបចំអនុវត្ត និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋចំនួន ប្រមាណជាងមួយលានបួនសែននាក់ ដែលក្នុងនោះ៥៤% គឺជាស្ត្រី។

តារាងសង្ខេបពីគម្រោងទ្រទ្រង់ជីវភាពសហគមន៍

| គម្រោង | ចំនួនកិច្ចសន្យា | តម្លៃកិច្ចសន្យា (លានដុល្លា) | អ្នកទទួលផល | |
|---|---|---|---|---|
| | | | សរុប | %ស្ត្រី |
| គម្រោងហេដ្ឋារចនាសម្ព័ន្ធ | 285 | 6.49 | 828,734 | 54 % |
| គម្រោងបង្កើនប្រាក់ចំណូល | 843 | 4.39 | 135,106 | 52 % |
| គម្រោងសហគមន៍នេសាទ | 284 | 1.02 | 506,982 | 53 % |
| សរុប | 1,412 | 11.90 | 1,470,822 | 54% |

សមិទ្ធផលរូបវន្តសំខាន់ៗនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធសង្គមខ្នាតតូចទាំងនោះរួមមាន ការសាងសង់ផ្លូវលំជនបទ ក្រាលក្រួសក្រហមមានប្រវែងសរុបចំនួន១៤៣គីឡូម៉ែត្រ ផ្លូវដីសចំនួន៩៦គីឡូម៉ែត្រ លូកាត់ថ្នល់ចំនួន៨៧កន្លែង ស្ពាន ចំនួន១១កន្លែង មានប្រវែងសរុបចំនួន១៤៥ម៉ែត្រ ស្ថានីយ៍ផ្គត់ផ្គង់ទឹកស្អាតចំនួន១៦កន្លែង ស្រះទឹកសហគមន៍ចំនួន១០ ទំនប់ទឹកប្រវែង៦០ម៉ែត្រ ស្ពានប្រឡាយប្រវែង២៧គីឡូម៉ែត្រ សាងសង់សាលារៀនចំនួន៥៤បន្ទប់ ផ្ទះសម្រាប់គ្រូ បង្រៀនចំនួន៥ខ្នង សាងសង់សាលាឃុំ សង្កាត់ចំនួន១៧ កាណូតឃុំសង្កាត់ចំនួន១៣ ការិយាល័យសហគមន៍នេសាទ វេទិកាសហគមន៍បណ្តែតទឹកចំនួន៤កន្លែង ទីផ្សារបណ្តែតទឹកចំនួន២កន្លែង ប៉ុស្តិ៍សុខភាពចំនួន២ និងស្ថានីយ៍អគ្គិសនី ជនបទមួយកន្លែងដែលមានសមត្ថភាពផ្គត់ផ្គង់អគ្គិសនីបានប្រមាណ២៥០គ្រួសារ។ គម្រោងនេះក៏បានគាំទ្រផងដែរ ដល់ការបំពាក់នូវប្រព័ន្ធអគ្គិសនីដោយប្រើពន្លឺព្រះអាទិត្យដល់សាលាឃុំចំនួន៣៤សាលាឃុំ បំពាក់កុំព្យូទ័រ និងគ្រឿង សង្ហារឹមដល់ឃុំ សង្កាត់គោលដៅទាំង៣៧ឃុំ។

ចំពោះគម្រោងបង្កើតប្រាក់ចំណូល ភាគច្រើនគឺជាគម្រោងចិញ្ចឹមសត្វ ដែលក្នុងនោះរួមមានជ្រូកចំនួន៥.៧៨៧ ក្បាល មាន់ចំនួនប្រមាណ៣៤.៤៤៤ក្បាល គោក្របីចំនួន១.៨១០ក្បាល កូនត្រី និងអន្ទង់ចំនួន៣១តោន សិប្បកម្ម

ផលិតទឹកត្រីរបស់សហគមន៍ចំនួន៣១៧គ្រួសារ ការបណ្តុះបណ្តាលវិជ្ជាជីវៈដូចជាជំនាញកាត់ដេរ កាត់សក់បុរសស្ត្រី ជំនាញក្នុងតែងការ ក្រុមជំនួញខ្នាតតូច ក្រុមឥណទាន និងក្រុមជួយខ្លួនឯង ក្រុមផលិតនំបញ្ចុក ក្រុមត្បាញកន្ទេល ក្រុមធ្វើគ្រឿងសង្ហារឹមពីឫស្សី ក្រុមភ្លេងបុរាណ ភ្លេងសម័យ ក្រុមដាំបន្លែ និងបណ្តុះផ្សិត ។ល ។

ចំពោះគម្រោងសហគមន៍នេសាទភាគច្រើន គឺផ្តោតលើការបំពាក់ឧបករណ៍ដល់សហគមន៍នេសាទ សម្រាប់ធ្វើការយាមល្បាតដែននេសាទឱ្យមានប្រសិទ្ធភាព ការអភិវឌ្ឍសមត្ថភាពសហគមន៍ដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍ប្រកបដោយនិរន្តរភាព និងការផ្សព្វផ្សាយចំណេះដឹងអំពីសារៈសំខាន់នៃធនធានធម្មជាតិ និងបរិស្ថានបឹងទន្លេសាប ។

<u>ការអភិវឌ្ឍសមត្ថភាព ពង្រឹងជំនាញ និងការទ្រទ្រង់ជីវភាពប្រកបដោយនិរន្តរភាព</u> ៖ ក្រៅពីសកម្មភាព រៀបចំ បង្កើត និងអនុវត្តមូលនិធិសហគមន៍ គម្រោងនេះក៏ផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍសមត្ថភាពស្ថាប័ន ជាពិសេសស្ថាប័ននៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់សហគមន៍ ក្រុមទទួលផលគម្រោង និងការពង្រឹងជំនាញរបស់សមាជិកក្រុមទទួលផលនានាផងដែរ ។

ក្រោមការសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ គម្រោងនេះបានគាំទ្រលើការផលិតឯកសារស្តីពីជម្រើសផ្នែកនយោបាយជាច្រើន ដែលផ្តោតទៅលើរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ស្តីពីបណ្តាញសុវត្ថិភាពសង្គម និងកិច្ចការពារសង្គមសម្រាប់ អ្នកទីទល់ក្រ និងជនងាយរងគ្រោះ ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានក្នុងក្រុមប្រឹក្សាស្តារវិស័យកសិកម្ម និងជនបទ និងការរៀបចំបង្កើតគេហទំព័ររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ។

ក្រោមកិច្ចសហការជាមួយក្រុមការងារអនុវត្តគម្រោងរបស់ក្រសួងបរិស្ថាន ក្នុងការអនុវត្តគម្រោងនេះក៏ទទួលលទ្ធផលគួរឱ្យកត់សម្គាល់ពាក់ព័ន្ធទៅនឹងការរៀបចំឯកសារសិក្សាវាយតម្លៃ ស្តីពីទស្សនទានរបស់ប្រជាពលរដ្ឋលើសារៈសំខាន់នៃធនធានធម្មជាតិ និងបរិស្ថាន ការរៀបចំឯកសារវីដេអូសម្រាប់ផ្សព្វផ្សាយអំពីបម្រែបម្រួលក្នុងការប្រើប្រាស់ធនធានធម្មជាតិបឹងទន្លេសាប និងអន្តរាគមន៍នានារបស់ក្រុមប្រឹក្សាឃុំ និងសហគមន៍នេសាទក្នុងការលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ ។ លើសពីនេះ ក៏មានសម្មភាពសំខាន់ជាច្រើនទៀត ដូចជាការរៀបចំឯកសារអប់រំបរិស្ថានសម្រាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹងបរិស្ថានដល់សហគមន៍មូលដ្ឋាន ។

ក្រោមកិច្ចសន្យាជាមួយវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល គម្រោងបានរៀបចំផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ឃុំ សង្កាត់គោលដៅ សហគមន៍នេសាទ និងស្ថាប័នពាក់ព័ន្ធនានាស្តីពីជំនាញសំខាន់ជាច្រើនដូចជាជំនាញគ្រប់គ្រងគម្រោង ការសរសេររបាយការណ៍ និងជំនាញសម្របសម្រួល ។

ក្រោមកិច្ចខិតខំប្រឹងប្រែងផ្ទាល់របស់ក្រុមការងារអនុវត្តគម្រោងរបស់ក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីក្រុមទីប្រឹក្សាអនុវត្តគម្រោង បានធ្វើការអភិវឌ្ឍសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់ និងពង្រីកចំណេះដឹង និងជំនាញលើប្រធានបទពាក់ព័ន្ធសំខាន់ៗរួមមាន ការចងក្រងសហគមន៍ សារៈសំខាន់នៃព័ត៌មានទីផ្សារ ការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់គម្រោង និងការយល់ដឹងពីទស្សនទាន និងការអនុវត្តសកម្មភាពយេនឌ័រនៅតាមសហគមន៍ ។

លើសពីនេះ ដើម្បីផ្សព្វផ្សាយចំណេះដឹងស្តីពីគោលនយោបាយ និងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដល់មន្ត្រីរាជការ សិស្ស និស្សិត និងសាធារណៈជនឱ្យបានទូលំទូលាយ គម្រោងនេះបានគាំទ្រដល់ការសាងសង់បណ្ណាល័យរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានទីតាំងនៅក្នុងក្រសួងមហាផ្ទៃ ព្រមទាំងបំពាក់គ្រឿងសង្ហារិម និងបរិក្ខារចាំបាច់នានា។

<u>ការរៀបចំ និងសិក្សាពីផលប៉ះពាល់របស់គម្រោង</u> ៖ ដើម្បីធ្វើការវាស់វែងអំពីឥទ្ធិផលរបស់គម្រោង ការសិក្សាអំពីផលប៉ះពាល់គម្រោងលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃការសិក្សាផ្ទៃក្នុង។ លទ្ធផលនៃការសិក្សានេះបានបង្ហាញឱ្យឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំផែនការ និងអនុវត្តគម្រោងមានការកើនឡើង និងមានភស្តុតាងជាច្រើនបង្ហាញថា ជីវភាពសហគមន៍នៅមូលដ្ឋានមានភាពប្រសើរឡើង លទ្ធភាពស្វែងរកទីផ្សារ និងព័ត៌មានទីផ្សារ បច្ចេកទេសថ្មី ហិរញ្ញវត្ថុជនបទ និងការផ្តល់សេវាមានលក្ខណៈប្រសើរជាងមុន។ អ្នកទទួលផលបានផ្តល់ព័ត៌មានថា មានការកើនឡើងប្រាក់ចំណូលដោយសារការលក់ដូរផលិតផល និងភាពប្រសើរឡើងផ្នែកជំនួញ និងមុខរបរ។ ក្រុមសន្សំមានលទ្ធភាពទទួលផ្តល់ដើមទុនសម្រាប់វិនិយោគបានចំណេញ។ ភាពប្រសើរឡើងនៃផ្នែកហេដ្ឋារចនាសម្ព័ន្ធ បាននាំឱ្យមានភាពប្រសើរឡើងផ្នែកសេវាកម្មសុខាភិបាល ការអប់រំ និងការធ្វើដំណើររបស់ប្រជាពលរដ្ឋទាំងនៅក្នុង និងក្រៅឃុំ។ ការសិក្សានេះក៏បានរកឃើញដែរថា មានការថយចុះលើភាពប្រថុយប្រថាន ភាពងាយរងគ្រោះ ព្រមទាំងចំនួនកម្មករចំណាកស្រុកផងដែរ។ បន្ថែមពីនេះ ការសិក្សាក៏បានរកឃើញថា បានចូលរួមចំណែកជាវិជ្ជមានដល់ការចូលរួមរបស់ស្ត្រី ក្រុមងាយរងគ្រោះ និងក្រុមជនជាតិភាគតិច ពិសេសក្នុងការរៀបចំគ្រប់គ្រងគម្រោង និងដឹកនាំក្រុមម្ចាស់គម្រោង។

<u>ការគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអត្រានុកូលដ្ឋាន</u> ៖ ក្រៅពីការរៀបចំបង្កើតមូលនិធិទ្រទ្រង់ជីវភាពសហគមន៍សម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍមូលដ្ឋាន និងការពង្រឹងសមត្ថភាពដូចបានរៀបរាប់ខាងលើ គម្រោងក៏បានគាំទ្រដល់ការគ្រប់គ្រង និងការបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងខេត្តគោលដៅគម្រោងទៅក្នុងប្រព័ន្ធកុំព្យូទ័របានចំនួន ១.៩៥៩.៥៨៣បញ្ជី។

## ២-ស្ថានភាពនៃការចំណាយថវិកាគម្រោង

ការគ្រប់គ្រង និងការចំណាយថវិការបស់គម្រោងភាគច្រើនត្រូវធ្វើឡើង នៅថ្នាក់មូលដ្ឋានក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅ។ មូលនិធិទ្រទ្រង់ជីវភាពសហគមន៍ចំនួន ១២.៣លានដុល្លារ ត្រូវបានចំណាយ១០០%។ រាល់ការចំណាយនានារបស់គម្រោងក៏ត្រូវបានធ្វើសវនកម្មជារៀងរាល់ឆ្នាំ ដោយសវនករឯករាជ្យ។ នាថ្ងៃបញ្ចប់គម្រោង (៣១ ខែធ្នូ ឆ្នាំ២០១០) ក្នុងចំណោមថវិកាគម្រោងសរុបចំនួន ២០.៣ លានដុល្លារអាមេរិក ត្រូវបានចំណាយអស់សរុបចំនួន ២០លានដុល្លារអាមេរិក និងសមតុល្យនៅសល់ចំនួន ៣០៥.៨៤២ ដុល្លារអាមេរិក។

## ៣-សេចក្តីសន្និដ្ឋាន

ការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប បានបញ្ចប់ការអនុវត្តទៅដោយជោគជ័យ ហើយមាន

ឥទ្ធិពលជាវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទោះបីជាមានការប្រឈមខ្លះៗក្នុងអំឡុងពេលនៃការអនុវត្តក៏ដោយ ។

គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប បានគាំទ្រ និងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវ ព្រមទាំងភាពជាម្ចាស់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជំរុញការចូលរួមរបស់សហគមន៍ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះក្នុងកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ។

គម្រោងបានចូលរួមចំណែកយ៉ាងធំធេង មិនត្រឹមតែលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់គោលដៅប៉ុណ្ណោះទេ តែដល់ការពង្រឹងសមត្ថភាពស្ថាប័ន បុគ្គលិក និងបុគ្គលពាក់ព័ន្ធនានាសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនាពេលអនាគត ។

បទពិសោធន៍ និងមេរៀនល្អៗនៃការអនុវត្តគម្រោងនេះ ពិសេសបទពិសោធន៍នៃការអនុវត្តគម្រោងបង្កើនប្រាក់ចំណូលក្រោមការគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ រួមជាមួយកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនបានផ្តល់ជាមេរៀន និងបទពិសោធន៍ដ៏មានសារៈសំខាន់សម្រាប់គម្រោងអភិវឌ្ឍន៍នានានៅពេលអនាគតរបស់រាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍មូលដ្ឋាននានា ។

ក្រសួងមហាផ្ទៃក៏បានធ្វើការផ្ទេរនូវរាល់សម្ភារៈ មធ្យោបាយធ្វើដំណើរ និងឧបករណ៍ទាំងអស់របស់គម្រោងជូនទៅរដ្ឋបាលខេត្តគោលដៅទាំង០៥ សម្រាប់ចាត់ចែងគ្រប់គ្រងបន្ត និងប្រើប្រាស់ដើម្បីជាប្រយោជន៍ក្នុងការគាំទ្រដល់និរន្តរភាពនៃសមិទ្ធផលគម្រោងទ្រទ្រង់ជីវភាពសហគមន៍នៅក្នុងឃុំគោលដៅ និងបំពេញតម្រូវការជាក់ស្តែងរបស់រដ្ឋបាលខេត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជ្រាបជារបាយការណ៍តាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ ។

**ប្រធាននាយកដ្ឋាន**